សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

Cambodia Microfinance Association

# ក្រមស្តីពីការផ្តល់ឥណទានប្រកបដោយសមធម៌

## ១. សេចក្តីផ្តើម

ក្រមស្តីពីការផ្តល់ឥណទានប្រកបដោយសមធម៌ ("ក្រម") ត្រូវបានសម្រេចឯកភាពដាក់ឲ្យអនុវត្តចំពោះសមាជិករបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានិងជាហត្ថលេខី ("គ្រឹះស្ថាន" ឬ "គ្រឹះស្ថានទាំងអស់") ដោយការប្តេជ្ញាចិត្តនិងសុច្ចន្ទៈខ្ពស់ តាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលរបស់សមាគម សំដៅពង្រឹងនូវគុណភាពនិងសមធម៌ នៃការផ្តល់សេវាឥណទានមីក្រូហិរញ្ញវត្ថុ ដើម្បីធានាសុខមាលភាពនិងនិរន្តរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ជម្រុញបរិយាប័ន្នហិរញ្ញវត្ថុនិងកាត់បន្ថយភាពក្រីក្រ ស្របតាមបេសកកម្មសង្គមរបស់វិស័យមីក្រូហិរញ្ញវត្ថុ និង គោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។

## ២. គោលបំណង

ក្រមនេះជាគំនិតផ្តួចផ្តើមរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ("សមាគម") ក្នុងគោលបំណងចម្បង បំពេញបន្ថែមនូវប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈនិងការទទួលខុសត្រូវរបស់គ្រឹះស្ថាន សំដៅពង្រឹងនូវគុណភាពនិងសមធម៌ នៃការផ្តល់សេវាឥណទានមីក្រូហិរញ្ញវត្ថុ ពោលគឺៈ

ក. ធានាការផ្តល់សេវាប្រកបដោយតម្លាភាព និងដោយមិនរើសអើង

ខ. ធានាផ្តល់ពត៌មានគ្រប់ជ្រុងជ្រោយ ជាពិសេសកាតព្វកិច្ចនិងសិទ្ធិរបស់អតិថិជន

គ. ធានាផ្តល់សេវាក្នុងតម្លៃសមរម្យជូនអតិថិជន ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជានិងគោលការណ៍គាំពារអតិថិជនជាមូលដ្ឋាន។

## ៣. ការផ្តល់សេវាឥណទានដោយតម្លាភាព

គ្រឹះស្ថានធានាផ្តល់សេវាឥណទានដោយតម្លាភាព ត្រឹមត្រូវនិងគ្មានចេតនាលាក់លៀមជូនអតិថិជនទោះក្នុងហេតុផលណាក៏ដោយ ជាពិសេសចំពោះអត្រាការប្រាក់និងកម្រៃសេវាពាក់ព័ន្ធនានា។ គ្រឹះស្ថានធានាផ្តល់សេវាដោយការគោរព ប្រកបដោយអធ្យាស្រ័យខ្ពស់ និងមិនត្រូវរើសអើង ពណ៌សម្បុរ ភេទ ដើមកំណើត។ល។ របស់អតិថិជននិងអ្នកពាក់ព័ន្ធ។

## ៤. ការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានដោយផ្ទាល់មាត់ (ដោយមានការពន្យល់) និងជាលាយល័ក្ខអក្សរឲ្យបានពិស្តារនិងទាន់ពេលវេលាជូនអតិថិជន ជាពិសេសត្រូវបញ្ជាក់ពីប្រភេទនៃឥណទាន(ជាសេវាឯកជនសុទ្ធសាធ) ពីកាតព្វកិច្ចនិងសិទ្ធិ (ទាំងអតិថិជន និងអ្នកធានា) និងជម្រើសនានាដែលអតិថិជនគួរយល់ដឹងក្នុងកាលៈទេសៈអាសន្ន ពុំអាចសងត្រឡប់ទាន់ពេលវេលា។ នីតិវិធីនិងគោលការណ៍នានាដែលត្រូវបានអនុវត្តត្រូវបញ្ជាក់ជូនឲ្យបានច្បាស់លាស់និងផ្តល់ជូនតាមការស្នើសុំរបស់អតិថិជន ឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

## ៥. ការផ្តល់សេវាក្នុងតម្លៃសមរម្យ

គ្រឹះស្ថានទាំងអស់ប្តេជ្ញាស្វះស្វែងរកមធ្យោបាយជាយុទ្ធសាស្ត្រនិងយុទ្ធវិធី បន្ទាបតម្លៃការប្រាក់និងកម្រៃសេវានានាឲ្យបានទាបបំផុតតាមដែលអាចធ្វើបានជាមួយភាគីពាក់ព័ន្ធគន្លឹះ រួចបង្វែរជូនអតិថិជន ដែលជាប្រជាពលរដ្ឋមានចំណូលទាប នូវអត្ថប្រយោជន៍នានាដែលជាសមិទ្ធិផលនៃប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ។ ក្នុងតំណាក់ការបច្ចុប្បន្នះ

ក. គ្រឹះស្ថានត្រូវអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមការកំណត់ពិដានអត្រាការប្រាក់ សម្រាប់ឥណទានជនបទ ពោលគឺ អត្រាការប្រាក់ ១៨% ប្រចាំឆ្នាំ ឬ ១,៥% ប្រចាំខែ ដោយគណនាផ្អែកលើសមតុល្យដែលនូវសល់។

ខ. គ្រឹះស្ថានត្រូវកំណត់កម្រៃសេវាសរុបមិនឲ្យលើសពី ៨%ក្នុងមួយឆ្នាំជាអតិបរមា សម្រាប់ទំហំឥណទានចំនួន៣០០០ដុល្លារឬទាបជាង(ឬសមមូលក្នុងរូបិយវត្ថុផ្សេង) និងកម្រៃសេវាសរុបមិនឲ្យលើសពី ៥%ក្នុងមួយឆ្នាំជាអតិបរមា សម្រាប់ទំហំឥណទានធំជាង៣០០០ដុល្លារ(ឬសមមូលក្នុងរូបិយវត្ថុផ្សេង) ដោយបត់បែនតាមការអនុវត្តរបស់គ្រឹះស្ថាននីមួយៗ។

គ. គ្រឹះស្ថានទាំងអស់ទទួលស្គាល់ថា កម្រៃសេវាមានភាពខុសគ្នាតាមប្រភេទកម្ចី ទំហំកម្ចី រូបិយវត្ថុ នឹងរយៈពេលកម្ចី ជាដើម ដោយពិនិត្យបន្ថែមឧបសម្ព័ន្ធទី១ លម្អិតបន្ថែមពីអត្រាការប្រាក់និងកម្រៃសេវា។

## ៦. អនុលោមភាពនិងការត្រួតពិនិត្យ

គ្រឹះស្ថានទាំងអស់ ធ្វើការវាយតម្លៃពីការអនុវត្តនិងអនុលោមភាពដោយខ្លួនឯង និងធ្វើជូនសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជានូវរបាយការណ៍ជាប្រចាំ (ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលសមាគម) ដោយភ្ជាប់នូវនិន្នន័យតាមតារាងដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី១។ ឧបសម្ព័ន្ធទី១ នេះអាចនឹងមានកែប្រែតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាលសមាគម ដែលក្នុងករណីនេះសមាគមនឹងជូនដំណឹងដល់គ្រឹះស្ថានដើម្បីអនុវត្ត។

គ្រឹះស្ថានត្រូវផ្តល់ព័ត៌មានបន្ថែមស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន តាមការស្នើសុំរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាតាមរយៈ **ប្រធានក្រុមប្រឹក្សាភិបាល** អោយបានទាន់ពេលវេលានិងត្រឹមត្រូវ។

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាតាមរយៈ **ប្រធានក្រុមប្រឹក្សាភិបាល** មានសិទ្ធិធ្វើរបាយការណ៍និងចែករំលែកនូវព័ត៌មានដែលទទួលបាន ជូននិយ័តករនិងគ្រឹះស្ថានពាក់ព័ន្ធសំខាន់ៗ ដើម្បីជាព័ត៌មាននិងសំណើចំណាត់ការសមស្របធានាពង្រឹងគោលបំណងចម្បងនិងការអនុវត្តនូវ **ក្រម** នេះ។

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាតាមរយៈ **ប្រធានក្រុមប្រឹក្សាភិបាល** មានសិទ្ធិចាត់តាំងគណៈកម្មការ ឬសវនករដើម្បីត្រួតពិនិត្យ និងវាយតម្លៃពីអនុលោមភាពរបស់គ្រឹះស្ថានឬគ្រឹះស្ថានទាំងអស់ តាមការសម្រេចជាឯកច្ឆ័ន្ទរបស់ក្រុមប្រឹក្សាភិបាលរបស់សមាគម ដែលរាល់ចំណាយទាំងអស់ជាបន្ទុករបស់គ្រឹះស្ថានសាមី។

គ្រឹះស្ថានទទួលខុសត្រូវចំពោះការអនុវត្តដែលប្រាសចាកពីប្រការនានានៃ ក្រម នេះនឹងព្រមទទួលពិន័យនានាតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ ក្នុងករណីសមាជិកណាមួយនៃក្រុមប្រឹក្សាភិបាលបានអនុវត្តខុស សមាជិកនោះពុំអាចចូលរួមក្នុងសេចក្តីសម្រេចកំណត់ពិន័យដល់គ្រឹះស្ថានខ្លួនឡើយ។

**៧. ប្រសិទ្ធិភាពនិងអវសានត្ត**

ក្រមនេះពុំមានគោលបំណងជាឯកសារឬឧបករណ៍ជំនួសឲ្យ ច្បាប់និងបទប្បញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា នីតិវិធីឬនិយាមឬគោលការណ៍នានា របស់គ្រឹះស្ថានឬដែលកំពុងអនុវត្តដោយគ្រឹះស្ថាន ទោះក្នុងក្របខណ្ឌណាក៏ដោយ។

ក្រុមប្រឹក្សាភិបាលសមាគម អាចលើកសំណើវិសោធនកម្ម ស្នើបន្ថែម ឬបញ្ជាក់ពីផ្នែកណាមួយ ឬទាំងស្រុង នៃ **ក្រម** នេះ ដែលនឹងត្រូវអនុម័តឡើងវិញជាឯកច្ឆ័ន្ទដោយគ្រឹះស្ថានទាំងអស់។

**ក្រម** នេះនឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ខែកក្កដា ឆ្នាំ២០១៧ ដោយមានគ្រឹះស្ថានជាហត្ថលេខីដូចមានភ្ជាប់តាមបញ្ជីហត្ថលេខីក្នុងឧបសម្ព័ន្ធទី២។

ឧបសម្ព័ន្ធទី១

# របាយការណ៍អត្រាការប្រាក់និងកម្រៃសេវា (Report on Interest Rate and Fees)

**As of 30 June 2017**

សូមផ្តល់ទិន្នន័យពិស្តារតាមភាពសមស្រប (Please breakdown the table when appropriate)

| Loan size (in USD or equivalent currency) | Maximum Interest Rate per Month | Maximum (One Time) Up Front Fee | Maximum Monthly Fee | Maximum Other Fee | TOTAL FEE | TOTAL PER YEAR |
|---|---|---|---|---|---|---|
| <=3,000 USD | | | | | 0.00% | 0.00% |
| >3,000 USD | | | | | 0.00% | 0.00% |

* កម្រៃសេវាទាំងអស់ខាងលើមិនរួមបញ្ចូលកម្រៃសេវានានារបស់ភាគីទី៣។